00755034

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 23 / 11 / 2011
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

E131/11

សាធារណៈ / Public

កាលបរិច្ឆេទ: ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១

**ជូនចំពោះ:** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** ការពន្យារពេលសវនាការពិនិត្យភស្តុតាងលើសំណុំរឿង ០០២ ជាបណ្ដោះអាសន្ន

នៅថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចរបស់ខ្លួនលើបញ្ហាសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ។ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាជនជាប់ចោទពុំមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការឡើយ និងបានបំបែកជនជាប់ចោទចេញពីកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ ដោយអនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង និងបានបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ពីមន្ទីរឃុំឃាំង អ.វ.ត.ក។

ទោះបីការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ក្នុងសំណុំរឿង ០០២ នឹងប្រព្រឹត្តទៅដូចតាមការគ្រោងទុកនៅវេលាម៉ោង ៩ ព្រឹក ថ្ងៃ ច័ន្ទ ទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ នៅឯបន្ទប់សវនាការធំនៃ អ.វ.ត.ក ក្ដី ក៏អង្គជំនុំជម្រះសាលាដំបូងយល់ថា ជាការចាំបាច់ដែលត្រូវពន្យារពេលសវនាការពិនិត្យភស្តុតាងជាបណ្ដោះអាសន្ន ដើម្បីឲ្យអង្គជំនុំជម្រះ និងភាគីមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រៀមរៀបចំសម្រាប់សវនាការនេះ។ អាស្រ័យហេតុនេះ សវនាការពិនិត្យភស្តុតាងនឹងប្រព្រឹត្តទៅនៅថ្ងៃ ច័ន្ទ ទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ វេលាម៉ោង ៩ ព្រឹក។

ដើម្បីជួយសម្រួលដល់ភាគីក្នុងការដោះស្រាយបញ្ហាបន្ទាន់នានាក្នុងការត្រៀមរៀបចំសម្រាប់សវនាការពិនិត្យភស្តុតាងនាពេលខាងមុខនោះ ជំនួបប្រជុំក្រៅផ្លូវការមួយរវាងភាគី និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំ-ជម្រះសាលាដំបូង នឹងធ្វើនៅថ្ងៃ សុក្រ ទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១។